Employment Security Department
WASHINGTON STATE

# ត្រឡប់ទៅធ្វើការវិញ

**ចំណុចសំខាន់៖** លក្ខខណ្ឌតម្រូវសម្រាប់ការស្វែងរកការងារ។
ចាប់ផ្ដើមសកម្មភាពស្វែងរកការងារនៅក្នុងសប្ដាហ៍នៃថ្ងៃទី4 ខែកក្កដា - ថ្ងៃទី10 ខែកក្កដា។ ចូលទៅកាន់ **ទំព័រលក្ខខណ្ឌតម្រូវសម្រាប់ការស្វែងរកការងារ** សម្រាប់ព័ត៌មានបន្ថែម។

ដើម្បីគាំទ្រដល់បុគ្គលិកនិងអាជីវកម្មតាមរយៈសេវាពេលគ្មានការងារធ្វើនិងចូលបម្រើការងារវិញ យើយផ្ដល់ជូន៖

- ឱកាសការងារនិងការបណ្ដុះបណ្ដាលសម្រាប់បុគ្គលិក៖
- ធនធានដែលត្រូវថែរក្សាកម្លាំងពលកម្មជំនាញសម្រាប់និយោជក។
- ព័ត៌មានស្ដីពីសិទ្ធិទទួលបានអត្ថប្រយោជន៍ពេលគ្មានការងារធ្វើ។
- ការណែនាំស្ដីពីការការស្នើសុំឲ្យវិលត្រឡប់ទៅធ្វើការវិញ
- ជាច្រើនផ្សេងទៀត។

# ការស្វែងរកការងារនៅអំឡុងវិបត្តិជំងឺ COVID-19

## ព័ត៌មានសម្រាប់បុគ្គលិក

### អ្នកត្រូវបានហៅឲ្យវិលត្រឡប់ទៅធ្វើការវិញ ប៉ុន្តែមិនអាចវិលត្រឡប់ទៅធ្វើការវិញទេបានមែនឬទេ?

ប្រសិនបើបច្ចុប្បន្ននេះអ្នកកំពុងទទួលបានអត្ថប្រយោជន៍ពេលគ្មានការងារធ្វើ ហើយមិនអាចត្រឡប់ទៅធ្វើការវិញបាននៅពេលត្រូវបានគេហៅឲ្យត្រឡប់ទៅធ្វើការវិញ (ទាំងការត្រឡប់ទៅកាន់ការងារចាស់ ឬទៅកាន់ការងារថ្មី) នោះយើងអាចជួយអ្នកឲ្យពិចារណាជម្រើសរបស់អ្នក។ ស្វែងយល់បន្ថែមទៀតអំពីពេលវេលាដែលអ្នកអាចបដិសេធឱកាសត្រឡប់ទៅធ្វើការ នៅលើ។

# ការស្វែងរកការងារបន្ទាប់របស់អ្នក

## WorkSource នៅទីនេះរង់ចាំផ្ដល់ជំនួយ

- ស្វែងរកឱកាសការងារសមស្របតាមរយៈ WorkSource Washington (ជាភាសាអង់គ្លេស)។ ដោយសារតែវិបត្តិនេះ ការិយាល័យ WorkSource នៅទូទាំងរដ្ឋបានបិទផ្អាកដំណើរការនាពេលបច្ចុប្បន្នសម្រាប់សេវាកម្មដោយផ្ទាល់ ប៉ុន្តែអ្នកនៅតែអាចទទួលបានជំនួយដោយទូរសព្ទទៅការិយាល័យក្នុងមូលដ្ឋាន ឬសាកសួរសំណួរតាមរយៈការជជែកពិភាក្សាផ្ទាល់។ ចូលទៅកាន់ WorkSourceWA.com (ជាភាសាអង់គ្លេស) សម្រាប់ព័ត៌មានបន្ថែម។
- ស្វែងយល់បន្ថែមអំពីឱកាសការងារនិងបណ្ដុះបណ្ដាលដែលផ្ដល់ជូនតាមរយៈ WorkSource System (ជាភាសាអង់គ្លេស)។
- សម្រិតសម្រាំងជំនាញដើម្បីទទួលបានការងារ សូមមើល សិក្ខាសាលានាពេលខាងមុខស្ដីពី WorkSourceWA (ជាភាសាអង់គ្លេស) នៅក្នុងតំបន់របស់អ្នក។
- ដើម្បីជានាសុវត្ថិភាពការងារសមស្រប សូមចូលរួម ព្រឹត្តិការណ៍ជួលបុគ្គលិក (ជាភាសាអង់គ្លេស)។

## ឱកាសបណ្ដុះបណ្ដាលការងារឡើងវិញ ឬ ឱកាសអប់រំ

- ស្វែងរកការអប់រំនិងការបណ្ដុះបណ្ដាលដែលអ្នកត្រូវការ ដើម្បីទទួលបានការងារដែលអ្នកចង់បានតាមរយៈ គេហទំព័រស្ពានតភ្ជាប់អាជីពការងារនៅរដ្ឋ Washington (Washington Career Bridge) (ជាភាសាអង់គ្លេស)។

- ប្រសិនបើអ្នកកំពុងពិចារណាវិលត្រឡប់ទៅសាលារៀនវិញ ឬទទួលបានការអប់រំបន្ថែមទៀត សូមចូលទៅកាន់ មហាវិទ្យាល័យ & ត្រីវិស័យអាជីពការងារនៅរដ្ឋ Washington (College & Career Compass Washington) (ជាភាសាអង់គ្លេស)។
- ចូលទៅកាន់ទំព័រ ស្វែងយល់អំពីមុខរបរ (Learn About an Occupation) (ជាភាសាអង់គ្លេស) សម្រាប់ការពិពណ៌នាអំពីការងារ លក្ខខណ្ឌតម្រូវការអប់រំ ប្រាក់បៀវត្សរ៍ ទំនោរនិងធនធានការងារ ឬដើម្បីស្វែងរកអាជីពការងារ។

## សិក្សាស្វែងយល់បន្ថែមអំពីវិស័យនានាដែលកំពុងជួលបុគ្គលិក

- មើល របាយការណ៍ការផ្គត់ផ្គង់/តម្រូវការ (Supply/Demand Report) (ជាភាសា អង់គ្លេស) សម្រាប់ការវិភាគភាពខ្វះចន្លោះទៅលើមុខរបរ រួមជាមួយនឹងការប្រៀបធៀបការបង្ហោះផ្សាយអំពីការងារប្រចាំខែតាមអនឡាញ និងទិន្នន័យរបស់នាយកដ្ឋានសន្តិសុខការងារអំពីអ្នកទាមទារសំណងជានារ៉ាប់រងពេលគ្មានការងារធ្វើ។
- ចូលទៅកាន់ទំព័រ ការងារនិងបណ្តុះបណ្តាល (Jobs and training) របស់យើង (ជាភាសាអង់គ្លេស) សម្រាប់ព័ត៌មានបន្ថែមអំពីការស្វែងរកការងារ។

*នាយកដ្ឋានសន្តិសុខការងារ គឺជាកម្មវិធី/និយោជកមួយដែលផ្តល់ឱកាសស្មើៗគ្នា។ ជំនួយបន្ថែមឬសេវាកម្មជំនួយ គឺអាចផ្តល់ជូនបានតាមសំណូមពរដល់ជនពិការ។ សេវាកម្មជំនួយផ្នែកភាសាសម្រាប់បុគ្គលដែលចេះអង់គ្លេសបន្តិចបន្តួច គឺមានផ្តល់ជូនដោយឥតគិតថ្លៃ។ សេវាកម្មបញ្ជូនបន្តនៃរដ្ឋ Washington ៖ 711*